ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

D:\B Chanda\Sara Da Ch.doc

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៤៨១ សរណន.កសក

# សារាចរណែនាំ

## ស្តីពីវិធានការទប់ស្កាត់ការដឹកជញ្ជូន និងធ្វើអាជីវកម្មដើមត្នោត

~~~~~~

ប្រជាជនខ្មែរយើងទាំងអស់គ្នាមានមោទនភាព និងកិត្យានុភាពយ៉ាងក្រៃលែង ដោយសារបុព្វបុរសយើងជាច្រើនជំនាន់កន្លងមក បានខិតខំតស៊ូព្យាយាមដាំដុះ ថែរក្សា និងការពាររហូតបានបន្សល់ទុកជាស្នាដៃកេរ្តិ៍តំណែលដ៏មានតម្លៃខាងសេដ្ឋកិច្ច វប្បធម៌ និងប្រវត្តិសាស្ត្រ ឱ្យដល់ជំនាន់យើងសព្វថ្ងៃនេះ នូវប្រភេទរុក្ខជាតិដើមត្នោតយ៉ាងច្រើនសន្ធឹកសន្ធាប់នៅពាសពេញក្នុងផ្ទៃប្រទេស ។ នាពេលបច្ចុប្បន្ននេះទៀតសោត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានសង្កេតឃើញបងប្អូនកសិករយើងនៅតាមខេត្ត-ក្រុងជាច្រើន ពិសេសបងប្អូនប្រជាកសិកដែលនៅជិតដងផ្លូវដឹកជញ្ជូនសំខាន់ៗ បាន និងកំពុងនាំគ្នាកាប់ដើមត្នោតយ៉ាងអនាធិបតេយ្យដើម្បីលក់ឱ្យឈ្មួញប្រមូលផ្តុំទិញ និង ដឹកជញ្ជូនយកទៅលក់បន្តនៅខេត្តព្រៃវែង ស្វាយរៀង និងតាកែវ ដែលខ្វះខាតឈើសាងសង់ ហើយទន្ទឹមនោះក៏នៅមានឈើត្នោតទាំងនោះមួយចំនួនធំបំផុតផងដែរ ដែលបាន និងកំពុងនាំចេញ ទៅលក់ជាបន្តទៀតនៅក្រៅប្រទេស ។ ករណីនេះកើតឡើងដោយសារមានឈ្មួញកណ្តាលជាអ្នកបំផុសឱ្យកាប់ និងដើរប្រមូលទិញធ្វើអាជីវកម្ម ដែលធ្វើឱ្យសកម្មភាពនេះកាន់តែវិវឌ្ឍន៍រីករាលដាលច្រើនឡើងៗពីតំបន់មួយទៅដល់តំបន់មួយទៀតជាបន្តបន្ទាប់ ។ ទង្វើខាងលើនេះ គឺដោយសារប្រជាកសិករខ្លះគិតថា ដើមត្នោតដុះក្នុងបរិវេណដីកម្មសិទ្ធិរបស់គាត់ គាត់មានសិទ្ធិប្រើប្រាស់ និងលក់ដូរទៅតាមតម្រូវការរបស់គាត់ដោយភ្លេចគិតដល់សារៈប្រយោជន៍ដ៏ច្រើនលើសលុបនៃដើមត្នោតដែលមានលើសពីរុក្ខជាតិផ្សេងៗ និង ជារុក្ខជាតិដែលតំណាងឱ្យប្រទេសជាតិកម្ពុជា និងតំណាងឱ្យព្រលឹងជាតិខ្មែរដូចដែលមានចម្លាក់នៅលើផ្ទាំងជញ្ជាំងអង្គរវត្តជាសក្ខីភាពស្រាប់ ។ នៅលើពិភពលោកជាពិសេសនៅភូមិភាគអាស៊ី គឺមានតែប្រទេសកម្ពុជាយើងទេដែលមានដើមត្នោតច្រើនជាងគេ ។

ដោយពិនិត្យឃើញពីផលប្រយោជន៍ខាងសេដ្ឋកិច្ច ប្រវត្តិសាស្ត្រ និងវប្បធម៌របស់ដើមត្នោតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សូមធ្វើការណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគ្រប់ខេត្ត-ក្រុង ដូចតទៅ :

១-ត្រូវធ្វើការផ្សព្វផ្សាយពីផលវិបាកនៃការបាត់បង់ដើមត្នោត ពីផលប្រយោជន៍ និងតម្លៃនៃដើមត្នោតជូនប្រជាពលរដ្ឋ ឱ្យបានយល់ជ្រួតជ្រាប ។

២-ត្រូវណែនាំបំផុសឱ្យប្រជាពលរដ្ឋបានយល់ដឹង និងចេះប្រើប្រាស់ដើមត្នោតឱ្យអស់លទ្ធភាព ហើយក្នុងករណីចាំបាច់យកមកប្រើប្រាស់ជាគ្រឿងសំណង់គ្រួសារផ្ទាល់នោះ គប្បីកាប់តែដើមត្នោតណាដែលមានអាយុច្រើនឬដែលលែងផ្តល់

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B.V.D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352; Fax : (855) 23 - 217 320
~~~~~~

ផល ហើយជៀសវាងការកាប់ដើមត្នោតនៅក្មេងកំពុងផ្តល់ផល ។ ក្នុងករណីនេះ ក៏ត្រូវណែនាំឱ្យដាំជួសវិញឱ្យបានយ៉ាងតិចទ្វេរដងដែរ ។

៣-ត្រូវជំរុញឱ្យប្រជាពលរដ្ឋខិតខំថែរក្សា និងដាំដើមត្នោតនៅលើដីទួលឬដីទំនេរ ដើម្បីជំនួសដើមត្នោតដែលបានកាប់យកមកប្រើប្រាស់ផង និងដើម្បីធានាទៅអនាគតយូរអង្វែងសំរាប់ប្រទេសកម្ពុជាយើងឱ្យនៅតែមានដុះដើមត្នោតដែលជាតំណាងអត្តសញ្ញាណជាតិយើងនេះដ៏ច្រើន និងពាសពេញគ្រប់ខេត្ត-ក្រុងទៀតផង ។

៤-ត្រូវសហការជាមួយអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ចុះ[illegible]ស្ថិតិដើមត្នោតរបស់ប្រជាកសិករនៅគ្រប់ភូមិ ឃុំ និងអប់រំណែនាំ និងហាមឃាត់ការកាប់ដើមត្នោត ដើម្បីធ្វើអាជីវកម្មលក់ដូរចេញទៅកាន់ខេត្តផ្សេងៗ ។

៥- ត្រូវសហការជាមួយសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែន ដើម្បីត្រួតពិនិត្យនិងហាមឃាត់ឱ្យបាននូវការនាំចេញឈើត្នោតទៅក្រៅប្រទេស ។

៦-មន្ត្រីនាយកដ្ឋានរុក្ខា-ប្រមាញ់ ដែលមានបេសកកម្មចុះត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រៃឈើទូទាំងប្រទេស ត្រូវចូលរួមអនុវត្តជាបន្ថែមឱ្យបានតឹងរឹងបំផុតក្នុងដែនសមត្ថកិច្ចរបស់ខ្លួននូវការងារត្រួតពិនិត្យជាប្រចាំ ត្រូវហាមឃាត់ និងទប់ស្កាត់រាល់ការដឹកជញ្ជូនឈើត្នោត និងដើមត្នោតចេញពីខេត្តមួយឆ្ពោះទៅកាន់ខេត្តក្រៅផ្សេងទៀត ដោយសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរពាក់ព័ន្ធ ។

ក្រោយពីទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវសហការឱ្យបានល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីចាត់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវខ្លឹមសារសារាចរណែនាំនេះ ។ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់នឹងចាត់វិធានការទប់ស្កាត់នូវការកាប់ និងការធ្វើអាជីវកម្មដឹកជញ្ជូនដើមត្នោតដោយអនាធិបតេយ្យ ដើម្បីរួមចំណែកក្នុងការការពាររុក្ខជាតិតំណាងឱ្យប្រទេសជាតិបានគង់វង្ស ជាមិនខាន ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៣

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

ចន្ទ.សារុន